ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ
លេខ :០៩៣៣/ក.អ.ជ
១៧

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០១៧

# របាយការណ៍

## វឌ្ឍនភាពការងារប្រចាំខែមិថុនា ឆ្នាំ ២០១៧ របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## I. សេចក្តីផ្តើម

ក្រសួងអភិវឌ្ឍន៍ជនបទបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តដើម្បីបុព្វហេតុជាតិមាតុភូមិ ពិសេសកសាងតំបន់ជនបទមួយឱ្យ ក្លាយជាតំបន់អភិវឌ្ឍន៍ប្រកបដោយសក្តានុពល និងបរិស្ថានអនាម័យល្អដើម្បីធានាសុខមាលភាពសុខសន្តិភាព ជូនប្រជាពលរដ្ឋពិសេសនៅតំបន់ជនបទ ។ ក្នុងខែមិថុនានេះ ក្រសួងអភិវឌ្ឍន៍ជនបទបានសម្រេចលទ្ធផលយ៉ាងច្រើន ដើម្បីបម្រើដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដូចជា ផ្លូវលំជនបទ ស្ពានបេតុង អណ្តូងទឹក ស្រះទឹក បង្គន់អនាម័យ ការផ្តល់ពូជសត្វចិញ្ចឹម ជីកស្រះចិញ្ចឹមត្រី ការផ្តល់ឥណទានសាច់ប្រាក់ ធនាគារស្រូវ ធនាគារសត្វ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ការអប់រំសុខភាពអនាម័យ យេនឌ័រ ការងារប្រយុទ្ធនឹងជំងឺអេដស៍ សកម្មភាពកុមារតូច សកម្មភាពបណ្តុះបណ្តាលសិទ្ធិស្តីពីជនពិការ ។ល។ ហើយលទ្ធផលទាំងនោះមានដូចខាងក្រោម ÷

## II. អំពីការងារគ្រប់គ្រងរបស់ក្រសួង

### ១. ការងាររដ្ឋបាល និងបុគ្គលិក

គិតរហូតមកដល់ត្រឹមដំណាច់ខែមិថុនា ឆ្នាំ ២០១៧ មន្ត្រីរាជការរបស់ក្រសួងសរុបចំនួន ១ ៧២៧ នាក់ (ស្ត្រី ៣៨២ នាក់) ÷

- មន្ត្រីគ្មានក្របខណ្ឌ (ថ្នាក់ដឹកនាំក្រសួង និងទីប្រឹក្សា) ចំនួន ៥៣ រូប (ស្ត្រី ០៦ រូប)
- មន្ត្រីរាជការក្របខណ្ឌក្រសួង ចំនួន ១ ៦៧៤ រូប (ស្ត្រី ៣៨២ រូប)
- មន្ត្រីរាជការថ្នាក់កណ្តាល ចំនួន ៥០២ រូប (ស្ត្រី ១៤០ រូប)
- មន្ត្រីរាជការថ្នាក់រាជធានី ខេត្ត ចំនួន ១ ១៧២ រូប (ស្ត្រី ២៤២ រូប)

ធៀបនឹងចំនួនមន្ត្រីរាជការកាលពីដំណាច់ខែឧសភា ឆ្នាំ ២០១៧ មានចំនួន ១ ៧៣៥ នាក់ នឹងមន្ត្រីរាជការសរុបបច្ចុប្បន្នរបស់ក្រសួងអភិវឌ្ឍន៍ជនបទមានការថយចុះចំនួន ០៨ នាក់។

ក្រសួងបានទទួលលិខិតចូលចំនួន ៧៩ ច្បាប់ លិខិតចេញក្រៅក្រសួងចំនួន ១៣៦ ច្បាប់ ចុះលេខប្រកាស និងសេចក្តីសម្រេចនានា ចំនួន ២០ ច្បាប់ និងលិខិតចុះលេខលិខិតបេសកកម្មចំនួន ៥៥៤ ច្បាប់ ។


អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 724 193
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com

**២. ក្រុមការងារចុះមូលដ្ឋានតាមដានការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣**

ក្នុងខែមិថុនា ឆ្នាំ ២០១៧ លេខាធិការដ្ឋានទទួលបានរបាយការណ៍ពីបណ្ដាមន្ទីរអភិវឌ្ឍន៍ជនបទ រាជធានី ខេត្ត ចំនួន ២២ អង្គភាព ។ ក្នុងខែមិថុនា មានសំណើ សំណូមពររបស់ប្រជាពលរដ្ឋនៅមូលដ្ឋានតាមរយៈវេទិកាសាធារណៈថ្នាក់ជាតិសរុប ចំនួន ១៥ ករណី (អាទិភាពខ្ពស់ចំនួន ០៨ ករណី) ក្នុងសំណើ សំណូមពរទាំង ១៥ ករណីខាងលើ ក្រសួងដោះស្រាយបានចំនួន ០៣ ករណី ។

**៣. ការងារផ្គត់ផ្គង់ និងហិរញ្ញវត្ថុ**

សរុបចំណាយខែមិថុនា ឆ្នាំ ២០១៧ របស់ក្រសួងធៀបនឹងច្បាប់ហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០១៧ សម្រេច÷

- ចំណាយចរន្តអនុវត្តបានចំនួន ១ ៩៦៩ ៥៦៦ ៦៩៩ រៀល ស្មើនឹង ១,៦៩% នៃច្បាប់ថវិកា
- ចំណាយមូលធនអនុវត្តបានចំនួន ០០ រៀល ស្មើនឹង ០០% នៃច្បាប់ថវិកា ។

**៤. ការងារផែនការ និងសហប្រតិបត្តិការអន្តរជាតិ**

- បន្តរៀបចំ និងកែសម្រួលផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៨-២០២០ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងសម្រេច
- រៀបចំប្រមូល និងចងក្រងទិន្នន័យគ្រប់អង្គភាពរាជធានី ខេត្ត និងថ្នាក់កណ្ដាលដើម្បីរៀបចំផែនការថវិកាប្រចាំឆ្នាំ ២០១៨ តាមសារាចរណែនាំលេខ ០០៣ សរណន ចុះថ្ងៃទី ០៩ មិថុនា ឆ្នាំ ២០១៧
- ត្រៀមរៀបចំសិក្ខាសាលា ស្ដីពីការផ្សព្វផ្សាយលទ្ធផលនៃការកសាងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៨-២០២០ និងការណែនាំស្ដីពីការរៀបចំផែនការថវិកាឆ្នាំ ២០១៨ របស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានជួបពិភាក្សាជាមួយអង្គការ PADEK ដើម្បីពិភាក្សាការងារមួយចំនួនទាក់ទងនឹងការបង្ការគ្រោះភ័យក្នុងសហគមន៍ និងការប្រែប្រួលអាកាសធាតុ
- ចូលរួមកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិនិត្យ និងកែសម្រួលសេចក្ដីព្រាងគោលការណ៍ណែនាំ ស្ដីពីការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ
- តាមដានការអនុវត្តថវិកាកម្មវិធីនៅខេត្តចំនួន ០២ គឺខេត្តក្រចេះ និងខេត្តកំពង់ឆ្នាំង
- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យផ្លូវជនបទ ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ និងគេហទំព័រក្រសួងអភិវឌ្ឍន៍ជនបទ
- បានផ្ដល់លិខិតគាំទ្រសុំអន្តរាគមន៍ ដើម្បីចុះបញ្ជីសុំស្លាកលេខ ONG សម្រាប់រថយន្តចំនួន ០២ គ្រឿង ជូនអង្គការ World Renew និងអង្គការ Samaritan Purse
- បានផ្ដល់លិខិតគាំទ្រសុំអន្តរាគមន៍ ដើម្បីនាំចូលរថយន្ត ចំនួន ០២ គ្រឿង ដោយការបង់ពន្ធ និងអាករជាបន្ទុករបស់រដ្ឋ ជូនអង្គការ Water Aid និងអង្គការការីតាស់អូស្ត្រាលី
- កំពុងដំណើរការកិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយអង្គការ SADP និងអង្គការ SGF ។

**៥. ការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

- ផ្សព្វផ្សាយការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៨-២០២០

- នាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងអភិវឌ្ឍន៍ជនបទ បានរៀបចំសិក្ខាសាលាស្តីពី "ការត្រួតពិនិត្យការអនុវត្តតាមអនុសាសន៍សវនកម្មផ្ទៃក្នុង" នៅសណ្ឋាគារ អេម៉ារីអូ នៃខេត្តមណ្ឌលគិរី ដែលប្រើប្រាស់ថវិកាទ្រទ្រង់ពីសហភាពអឺរ៉ុប (PFM) ។

**៦. ការងារអធិការកិច្ច និងសវនកម្ម**

- បានចុះធ្វើអធិការកិច្ចលើការងារគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ នៅមន្ទីរអភិវឌ្ឍន៍ជនបទ ចំនួន ០៣ គឺ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ និងខេត្តសៀមរាប
- បានចុះធ្វើសវនកម្មលើការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ថវិកាតាមកម្មវិធីឆ្នាំ ២០១៦-២០១៧ និងចុះពិនិត្យជាក់ស្តែងការងារសាងសង់ ជួសជុលអណ្តូងទឹក និងសាងសង់បង្គន់អនាម័យ ដោយប្រើប្រាស់ថវិការដ្ឋនៅមន្ទីរអភិវឌ្ឍន៍ជនបទចំនួន ០៤ គឺ ខេត្តកោះកុង កំពង់ស្ពឺ ពោធិ៍សាត់ និងខេត្តបន្ទាយមានជ័យ។

## III. សកម្មភាពការងារជំនាញ

**១. ការងារអភិវឌ្ឍន៍ផ្លូវជនបទ**

- គម្រោងសាងសង់ ជួសជុលផ្លូវ និងសំណង់សិល្បការ ដោយប្រើប្រាស់ថវិកាជំពូក ២១ មាន ៦៧ គម្រោង រួមមាន÷
  - ផ្លូវក្រាលកៅស៊ូ DBST ចំនួន ១៦ ខ្សែ ប្រវែង ៨១,៣៣ គ.ម
  - ផ្លូវក្រាលបេតុង ចំនួន ០៥ ខ្សែ ប្រវែង ១១,៩៥ គ.ម
  - ផ្លូវក្រាលក្រួស ចំនួន ៤១ ខ្សែ ប្រវែង ៣៦៣,៩៥ គ.ម
  - លូមូល ចំនួន ២៣០ កន្លែង
  - លូជ្រុង ចំនួន ៤៥ កន្លែង
  - ស្ពានបេតុង ចំនួន ២០ ប្រវែង ៤៣៨ ម៉ែត្រ

បាន និងកំពុងដំណើរការការដ្ឋានចំនួន ៤៣ គម្រោង លទ្ធផលគិតជាមធ្យមស្មើនឹង ៤៥ %

- គម្រោងថែទាំផ្លូវលក្ខណៈខួប ដោយប្រើប្រាស់ថវិកាជំពូក ៦១ មាន ៨២ គម្រោង រួមមាន÷
  - ផ្លូវក្រាលកៅស៊ូ ចំនួន ០៤ ខ្សែ ប្រវែង ៧,៤៥៤ គ.ម
  - ផ្លូវក្រាលក្រួស ចំនួន ៧៥ ខ្សែ ប្រវែង ៤៨៩,៧១ គ.ម
  - លូមូល ចំនួន ១០៤ កន្លែង
  - លូជ្រុង ចំនួន ០៥ កន្លែង

សម្រេចបានលទ្ធផលគិតជាមធ្យមស្មើនឹង ៥៣%

- គម្រោងថែទាំផ្លូវលក្ខណៈប្រចាំ ដោយប្រើប្រាស់ថវិកាជំពូក ៦១ មាន ១៦១ គម្រោង រួមមាន ÷
  - ផ្លូវក្រាលកៅស៊ូ ចំនួន ២៣ ខ្សែ ប្រវែង ៤៣៣,៤០ គ.ម
  - ផ្លូវក្រាលក្រួសចំនួន ១៣៨ ខ្សែ ប្រវែង ១ ១៣៩,២១ គ.ម
  - ស្លាកចរាចរ ចំនួន ១ ០៦៧ ស្លាក

សម្រេចលទ្ធផលគិតជាមធ្យមស្មើនឹង ២១ % ។

**២. ការងារផ្គត់ផ្គង់ទឹកជនបទ**

- សាងសង់អណ្តូងល្អ ចំនួន ០៤ អណ្តូង នៅខេត្តពោធិ៍សាត់
- ជួសជុលអណ្តូងល្អ ចំនួន ១៣ អណ្តូង នៅខេត្តកោះកុង
- សាងសង់អណ្តូងស្នប់ ចំនួន ១៣ អណ្តូង នៅខេត្តបាត់ដំបង និងខេត្តស្វាយរៀង
- ជួសជុលអណ្តូងស្នប់ ចំនួន ២១ អណ្តូង នៅខេត្តស្ទឹងត្រែង កោះកុង ព្រះសីហនុ បាត់ដំបង និងរតនគីរី
- សាងសង់ស្រះសហគមន៍ ចំនួន ០២ នៅខេត្តកោះកុង ។

**៣. ការងារថែទាំសុខភាព និងអនាម័យជនបទ**

- បានធ្វើយុទ្ធនាការផ្សព្វផ្សាយធ្វើឱ្យប្រសើរឡើងនូវអនាម័យជនបទតាមភូមិគោលដៅ ក្នុងខេត្តទាំង ១៣ គឺខេត្តកំពង់ចាម កំពង់ឆ្នាំង ត្បូងឃ្មុំ បាត់ដំបង ព្រះសីហនុ កោះកុង ក្រចេះ កំពង់ស្ពឺ កំពត ប៉ៃលិន សៀមរាប ស្ទឹងត្រែង និងខេត្តស្វាយរៀង សរុបចំនួនអ្នកចូលរួម ១១ ១៦៨ នាក់ ស្ត្រីចំនួន ៨ ១៩០នាក់
- បានពិនិត្យការផលិតសម្ភារបង្គន់ និងការសាងសង់បង្គន់អនាម័យតាមភូមិគោលដៅ ក្នុងខេត្តទាំង ០៦ គឺខេត្តក្រចេះ បាត់ដំបង កំពង់ស្ពឺ ព្រះសីហនុ សៀមរាប និងខេត្តស្វាយរៀង
- ក្រុមការងារកម្មវិធីសហគមន៍ដឹកនាំអនាម័យ បានចូលរួមជួយបំផុសសកម្មភាពអនាម័យតាមភូមិគោលដៅ ក្នុងឃុំចំនួន ០៣ នៅខេត្តមណ្ឌលគិរី ខេត្តរតនគីរី និងខេត្តសៀមរាប មានអ្នកចូលរួមបំផុស ចំនួន ១៩៨ នាក់ ក្នុងនោះមានកុមារ ១៤៤ នាក់ និងមានអ្នកស្ម័គ្រចិត្តផ្លាស់ប្តូរឥរិយាបថ ចំនួន ៨៤ នាក់ ។

**៤. ការងារអភិវឌ្ឍន៍សហគមន៍**

- រៀបចំឯកសារគោលការណ៍ណែនាំ ស្តីពីដំណើរការអភិវឌ្ឍន៍ភូមិចម្រុះសម្រាប់ជាភូមិគំរូ ឆ្នាំ ២០១៨
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ បានបើកវគ្គបណ្តុះបណ្តាលក្នុង និងក្រៅមជ្ឈមណ្ឌល ចំនួន ០៤ មុខជំនាញ មានសិក្ខាកាមចំនួន ១២០ នាក់ ស្រី ៦៨ នាក់
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តតាកែវ បានបើកវគ្គភាសាអង់គ្លេស ចំនួន ០២ វគ្គ មានសិក្ខាកាមសរុបចំនួន ៦៦ នាក់ ស្រី ៤៥ នាក់
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តព្រៃវែង បាន និងកំពុងដំណើរការវគ្គបណ្តុះបណ្តាលចំនួន ០៧ វគ្គ មានសិក្ខាកាមសរុប ១៨៥ នាក់ ស្រី ១៤៥ នាក់
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តស្វាយរៀង បាន និងកំពុងដំណើរការវគ្គបណ្តុះបណ្តាលចំនួន ០៧ វគ្គ មានសិក្ខាកាមសរុប ១៥៣ នាក់ ស្រី ៦៤ នាក់
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម បានចាប់ផ្តើមវគ្គបណ្តុះបណ្តាល ចំនួន ០៤ វគ្គ មានសិក្ខាកាមសរុបចំនួន ១០៨ នាក់ ស្រី ៥២ នាក់

- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តបាត់ដំបង បានបន្តដំណើរការវគ្គបណ្តុះបណ្តាលចំនួន ០៧ វគ្គ ដែលមានសិក្ខាកាមសរុបចំនួន ១៣៤នាក់ ស្រី ៦៣ នាក់
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តពោធិ៍សាត់ បានបើកវគ្គបណ្តុះបណ្តាលជំនាញមូលដ្ឋានចំនួន ០៣ វគ្គ ដែលមានសិក្ខាកាមសរុបចំនួន ៦៥ នាក់ ស្រី ៤៥ នាក់
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពត បានបន្តដំណើរការវគ្គបណ្តុះបណ្តាលចំនួន ០៥ វគ្គ ដែលមានសិក្ខាកាមចំនួន ៨១ នាក់ ស្រី ២៣ នាក់។

**៥. ការងារបណ្តុះបណ្តាល**

- មន្ត្រីចូលរួមសិក្ខាសាលាក្នុងប្រទេស ចំនួន ១០៨ នាក់ ក្នុងនោះស្រី ១៨ នាក់
- មន្ត្រីចូលរួមសិក្ខាសាលាក្រៅប្រទេស ចំនួន ០៥ នាក់ ក្នុងនោះស្រី ០១ នាក់
- មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្នុងប្រទេស ចំនួន ៥៧ នាក់ ក្នុងនោះស្រី ១១ នាក់
- មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេស ចំនួន ០២ នាក់ ក្នុងនោះស្រី ០១ នាក់
- រៀបចំឯកសារចាត់បញ្ជូនមន្ត្រីចំនួន ០៣ រូប ដើម្បីចូលរួមវគ្គបណ្តុះបណ្តាល
- ផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការប្រកួតប្រជែងពានរង្វាន់ ICT កម្ពុជា ឆ្នាំ ២០១៧
- បានរៀបចំបញ្ជីសំណួរនាំមុខ សម្រាប់សិក្សាស្រាវជ្រាវ "តម្រូវការការអភិវឌ្ឍសមត្ថភាពការងាររបស់ការិយាល័យជំនាញ នៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត" ។

**៦. ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ**

- គិតត្រឹមថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០១៧ ប្រតិបត្តិករឥណទានជនបទដែលមន្ទីរអភិវឌ្ឍន៍ជនបទខេត្តអនុវត្តផ្ទាល់ និងសហការជាមួយដៃគូ និងសកម្មភាពការងារឥណទានដែលអនុវត្តដោយសហគមន៍សន្សំប្រាក់ បានផ្តល់ឥណទានសរុបចំនួន ៥ ២២៤ ៤៦៣ ០០០ រៀល (ប្រាំប៊ីលានពីររយម្ភៃបួនលានបួនរយហុកសិបបីពាន់រៀល) ស្មើនឹង ១ ៣០៦ ១១៥,៧៥ ដុល្លារអាមេរិក (មួយលានបីរយប្រាំមួយពាន់មួយរយដប់ប្រាំដុល្លារនិងចិតសិបប្រាំសេន) (១ USD=៤០០០ រៀល) មានអ្នកខ្ចីសរុបចំនួន ៦ ០១៥ នាក់ នៅភូមិគោលដៅចំនួន ២១៩ ភូមិ ៧៩ ឃុំ ៣៤ ស្រុក ក្នុងខេត្តគោលដៅចំនួន ១៥
- មន្ទីរអភិវឌ្ឍន៍ជនបទខេត្តស្វាយរៀង បានធ្វើការបូកសរុប និងសម្របសម្រួលគាំទ្រផ្នែកបច្ចេកទេសគ្រប់គ្រងធនាគារស្រូវដល់សហគមន៍ដែលមានស្រូវសរុបចំនួន ១៥ ៦០០ គ.ក្រ គិតជាទឹកប្រាក់ស្មើនឹង ២ ៧៣០ ដុល្លារអាមេរិក (ពីរពាន់ប្រាំពីររយសាមសិបដុល្លារអាមេរិក) ស្ថិតនៅក្នុងជង្រុក ។

**៧. ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច**

- បានបញ្ចូលទិន្នន័យភូមិក្លងខ្មៅ ឃុំសុខសាន្ត ស្រុកកោះញែក ខេត្តមណ្ឌលគិរី ដែលទទួលស្គាល់ដោយក្រសួងអភិវឌ្ឍន៍ជនបទក្នុងតារាងបញ្ជី

- រៀបចំឯកសារលទ្ធផលស្រាវជ្រាវវាយតម្លៃដែលសហគមន៍បានស្នើសុំ លើលក្ខណៈវិនិច្ឆ័យអត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចជង ភូមិកោះ ភូមិព្រែកស្វាយ ឃុំថ្មដូនពៅ និងភូមិច្រកឬស្សី ឃុំជីនាប់ ស្រុកថ្មបាំង ខេត្តកោះកុង ដើម្បីសុំទទួលស្គាល់ពីក្រសួងអភិវឌ្ឍន៍ជនបទ
- សម្របសម្រួលក្រុមការងារ កំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច របស់មន្ទីរអភិវឌ្ឍន៍ជនបទ ជាមួយអង្គការ UNOHCHR ក្នុងការរៀបចំសហគមន៍ជនជាតិដើមភាគតិចព្នង ភូមិចឹង ឃុំឃ្សឹម ស្រុកស្នួល ខេត្តក្រចេះ ។

**៨. ការងារយេនឌ័រ**

- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្ដីពីទស្សនៈយេនឌ័រ និងអនុសញ្ញា ស៊ី-ដ និង អនុសាសន៍របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ឆ្នាំង ។

**៩. ការងារប្រយុទ្ធនឹងជំងឺអេដស៍**

- ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសប្រចាំខែរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រោមអធិបតីភាពរបស់ **ឯកឧត្តមវេជ្ជបណ្ឌិត តែង គន្ធី អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍** មានសមាសភាពចូលរួមមកពីក្រុមប្រឹក្សាបច្ចេកអន្តរក្រសួង នៅសាលប្រជុំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**១០. ក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការ**

- ប្រជុំពិភាក្សា កែសម្រួលកម្រងសំណួរ ដើម្បីចុះសិក្សាវាយតម្លៃ ការអនុវត្តគម្រោងដើម្បីសាកល្បងមុខងារអនាម័យជនបទដល់ថ្នាក់ក្រោមជាតិ ជាមួយទីប្រឹក្សាធនាគារពិភពលោក ទីប្រឹក្សាធនាគារអភិវឌ្ឍន៍អាស៊ី និងមន្ត្រីលេខាធិការដ្ឋាន គ.ជ.អ.ប
- រៀបចំលិខិតប្រកាស និងកិច្ចព្រមព្រៀង សម្រាប់បន្តអនុវត្តគម្រោងផ្ទេរសាកល្បងមុខងារអនាម័យជនបទ មុខងារថែទាំប្រព័ន្ធទឹកស្អាត និងមុខងារថែទាំផ្លូវជនបទ ដល់អភិបាលស្រុក ថ្នាក់ក្រោមជាតិ។

## III. ការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការផ្សេងៗ

**១. គម្រោងកែលម្អផ្លូវជនបទ ដំណាក់កាល ២**

អនុវត្តក្នុងខេត្តគោលដៅចំនួន ១០ គឺ ខេត្តត្បូងឃ្មុំ កំពង់ចាម តាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ ។

- ខេត្តត្បូងឃ្មុំ : កំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ ខ្សែ ក្នុងចំណោមខ្សែផ្លូវទាំង ០៩ ខ្សែ ដែលមានប្រវែងសរុប ១៩៣,៩ គ.ម
- ខេត្តកំពង់ចាម : កំពុងដំណើរការសាងសង់ផ្លូវក្រាលបេតុងចំនួន ០៤ ខ្សែ ប្រវែង ៤៥,២៤ គ.ម ក្នុងចំណោម ០៥ ខ្សែ ដែលមានប្រវែងសរុប ៥០ គ.ម
- ខេត្តកំពង់ស្ពឺ : កំពុងដំណើរការសាងសង់ផ្លូវចំនួន ០៣ ខ្សែ ប្រវែង ៧៥,២០ គ.ម ក្នុងចំណោម ០៩ ខ្សែ ដែលមានប្រវែងសរុប ១៦៣,៧ គ.ម

- ខេត្តតាកែវ : កំពុងដំណើរការសាងសង់ផ្លូវចំនួន ០២ ខ្សែ ប្រវែង ៣៧,៣៣ គ.ម ក្នុងចំណោម ០៩ ខ្សែ ដែលមានប្រវែងសរុប ១០៤,៤ គ.ម
- ខេត្តកំពង់ឆ្នាំង : កំពុងដំណើរការសាងសង់ផ្លូវចំនួន ០៣ ខ្សែ ប្រវែង ៣៨,៨០ គ.ម ក្នុងចំណោម ០៩ ខ្សែ ដែលមានប្រវែងសរុប ១២៥,៩ គ.ម
- ខេត្តកំពង់ធំ : កំពុងដំណើរការសាងសង់ផ្លូវចំនួន ០១ ខ្សែប្រវែង ៤០,៨ គ.ម ក្នុងចំណោម ០៤ ខ្សែ មានប្រវែងសរុប ១២២,៧ គ.ម
- ខេត្តសៀមរាប : កំពុងដំណើរការសាងសង់ផ្លូវចំនួន ០២ ខ្សែ ប្រវែង ៤៦,៥ គ.ម ក្នុងចំណោម ០២ ខ្សែ ដែលមានប្រវែងសរុប ១២២ គ.ម
- ខេត្តបាត់ដំបង : កំពុងដំណើរការសាងសង់ផ្លូវចំនួន ០៥ ខ្សែ ប្រវែង ៧៥,១០ គ.ម ក្នុងចំណោម ០៧ ខ្សែ ដែលមានប្រវែងសរុប ៩៤,៨ គ.ម
- ខេត្តពោធិ៍សាត់ : កំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ ខ្សែ ប្រវែង ១២០,៤ គ.ម នៃខ្សែផ្លូវទាំង ១០ ខ្សែ ដែលមានប្រវែងសរុប ១២៥,៥ គ.ម
- ខេត្តបន្ទាយមានជ័យ : កំពុងដំណើរការសាងសង់ផ្លូវចំនួន ០៥ ខ្សែ នៃខ្សែផ្លូវទាំង ០៥ខ្សែ ដែលមានប្រវែងសរុប ៩០,៧ គ.ម ។

**២. គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទដំណាក់កាលទី ៤**

កំពុងអនុវត្តនៅខេត្តគោលដៅចំនួន ០៤ គឺ ខេត្តបាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ និង ខេត្តព្រះវិហារ។

- ខេត្តបន្ទាយមានជ័យ : បាន និងកំពុងសាងសង់ផ្លូវក្រាលក្រួសក្រហម និងកៅស៊ូពីរជាន់ចំនួន ០២ ខ្សែ ប្រវែង ៣៣,២០ គ.ម សម្រេចបាន ៣៦%
- ខេត្តបាត់ដំបង : បាន និងកំពុងសាងសង់ផ្លូវក្រាលក្រួសក្រហម និងកៅស៊ូពីរជាន់ចំនួន ០៣ ខ្សែ ប្រវែង ៣៦,៦០ គ.ម សម្រេចបាន ៥៥%
- ខេត្តឧត្តរមានជ័យ : បាន និងកំពុងសាងសង់ផ្លូវក្រាលក្រួសក្រហម និងកៅស៊ូពីរជាន់ចំនួន ០១ ខ្សែ ប្រវែង ១៦,០០ គ.ម សម្រេចបាន ៦០%
- ខេត្តព្រះវិហារ : បាន និងកំពុងសាងសង់ផ្លូវក្រាលកៅស៊ូពីរជាន់ចំនួន ០៣ ខ្សែ ប្រវែង ៤៨,៧០ គ.ម សម្រេចបាន ២៧% ។

**៣. គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចដើម្បីធានាចីរភាពក្នុងការអនុវត្តកំណែទម្រង់ដីធ្លី (IPLR)**

កំពុងអនុវត្តនៅខេត្តគោលដៅចំនួន ០៥ គឺ ខេត្តកំពង់ឆ្នាំង កំពង់ធំ ក្រចេះ មណ្ឌលគិរី និងខេត្តរតនគិរី ។

- ខេត្តកំពង់ឆ្នាំង ÷
    - បានបញ្ចប់ការសាងសង់ផ្លូវក្រាលក្រួសក្រហម ០២ ខ្សែ ប្រវែង ២០,២៨៥ គ.ម
    - សាងសង់អណ្តូងស្នប់ ចំនួន ១២ អណ្តូង នៅស្រុកសាមគ្គីមានជ័យ

- បានបញ្ចប់ការសាងសង់សាលាបឋមសិក្សាចំនួន ០១ ខ្នង ស្មើនឹង ០៣ បន្ទប់ ស្ថិតក្នុងភូមិសំបុកគ្រៀល ឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ

- ខេត្តកំពង់ធំ ÷
  - បានបញ្ចប់ការសាងសង់ផ្លូវក្រាលក្រួសក្រហម និងផ្លូវក្រាលកៅស៊ូពីរជាន់ប្រភេទ DBST ០១ ខ្សែ ប្រវែងសរុប ២៣,១០០ គ.ម
  - សាងសង់អណ្តូងល្អ ចំនួន ២៤ អណ្តូង នៅស្រុកសន្ទុក
- ខេត្តក្រចេះ : បានបញ្ចប់ការសាងសង់ផ្លូវក្រាលក្រួសក្រហម ០២ ខ្សែ ប្រវែងសរុប ២២,៨០ គ.ម
- ខេត្តមណ្ឌលគិរី ÷
  - បាន និងកំពុងសាងសង់ផ្លូវក្រាលក្រួសក្រហម ០១ ខ្សែ ប្រវែងសរុប ៨,៦៧២ គ.ម សម្រេចបាន ៩០%
  - បានបញ្ចប់ការសាងសង់សាលាបឋមសិក្សាចំនួន ០១ ខ្នង ស្មើនឹង ០៥ បន្ទប់ ស្ថិតក្នុងឃុំស្រែខ្ទុម ស្រុកកែវសីមា
- ខេត្តរតនគិរី ÷
  - បានបញ្ចប់ការសាងសង់ផ្លូវក្រាលក្រួសក្រហម ០១ ខ្សែប្រវែង ៧០០ ម៉ែត្រ នៅភូមិក្រឡា ឃុំប៉ូយ ស្រុកអូរជុំ
  - បានបញ្ចប់ការសាងសង់សាលាបឋមសិក្សាចំនួន ០១ ខ្នង ស្មើនឹង ០៣ បន្ទប់ ស្ថិតក្នុងភូមិឡាអ៊ឺនស្រែ ឃុំតឺន ស្រុកកូនមុំ ។

**៤. គម្រោងស្តារឡើងវិញបន្ទាន់នូវហេដ្ឋារចនាសម្ព័ន្ធរូបវន្តខូចខាតដោយគ្រោះទឹកជំនន់ឆ្នាំ ២០១៣**

អនុវត្តនៅខេត្តគោលដៅចំនួន ០៦ គឺ ខេត្តត្បូងឃ្មុំ កំពង់ចាម កំពង់ធំ សៀមរាប បន្ទាយមានជ័យ និងខេត្តបាត់ដំបង ។

- ខេត្តត្បូងឃ្មុំ : ជួសជុលផ្លូវចំនួន ០៨ ខ្សែ មានប្រវែងសរុប ១៨,៩ គ.ម ក្រាលបេតុងប្រវែង ៧ ៦១៧,៥ ម៉ែត្រ លូមូល ២១ កន្លែង លូប្រអប់ ០៥ កន្លែង និងស្ពាន ០១ កន្លែង ។ បានពិនិត្យ និងវាយតម្លៃបញ្ចប់ការងារសាងសង់ ចំនួន ០៣ ខ្សែ
- ខេត្តកំពង់ចាម : ជួសជុលផ្លូវចំនួន ០៥ ខ្សែ មានប្រវែងសរុប ១៦,៩ គ.ម ក្រាលបេតុងប្រវែង ៤ ៩៧៨,៩ ម៉ែត្រ និងលូមូល ១៤ កន្លែង បានពិនិត្យ និងវាយតម្លៃបញ្ចប់ការងារសាងសង់រួច
- ខេត្តកំពង់ធំ : ជួសជុលផ្លូវចំនួន ០៣ ខ្សែ មានប្រវែងសរុប ១៦,៦ គ.ម ក្រាលបេតុងប្រវែង ៥ ៧២០ ម៉ែត្រ លូមូល ១៦ កន្លែង និងលូប្រអប់ ០៤ កន្លែង បានពិនិត្យ និងវាយតម្លៃបញ្ចប់ការងារសាងសង់រួច
- ខេត្តសៀមរាប : ជួសជុលផ្លូវចំនួន ០៣ ខ្សែ មានប្រវែងសរុប ២៤,២ គ.ម ក្រាលបេតុងប្រវែង ៩ ០៩០ ម៉ែត្រ លូមូល ២៥ កន្លែង និងលូប្រអប់ ១១ កន្លែង។ បានពិនិត្យ និងវាយតម្លៃបញ្ចប់ការងារសាងសង់ ចំនួន ០១ ខ្សែ

- ខេត្តបន្ទាយមានជ័យ : ផ្លូវជុលផ្លូវចំនួន ០៤ ខ្សែ មានប្រវែងសរុប ៤១ គ.ម ក្រាលបេតុងប្រវែង ៧ ៦៤៦ ម៉ែត្រ លូមូល ២៤ កន្លែង និងលូប្រអប់ ០៧ កន្លែង។ បានពិនិត្យ និងវាយតម្លៃបញ្ចប់ការងារសាងសង់ ចំនួន ០៣ ខ្សែ
- ខេត្តបាត់ដំបង : ជួសជុលផ្លូវចំនួន ០៣ ខ្សែ មានប្រវែងសរុប ២៤,៣ គ.ម ក្រាលបេតុងប្រវែង ៨ ០១០ ម៉ែត្រ លូមូល ២២ កន្លែង និងលូប្រអប់ ០៤ កន្លែង បានពិនិត្យ និងវាយតម្លៃបញ្ចប់ការងារសាងសង់រួច ។

**៥. គម្រោងឥណទានខ្នាតតូច**

គិតត្រឹមថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០១៧ គម្រោងឥណទានខ្នាតតូចដែលគាំទ្រថវិកាដោយវិទ្យាស្ថានសេដ្ឋកិច្ចជនបទកូរ៉េ បានផ្តល់ឥណទានសរុបចំនួន ៣៨៧ ៧៧៣ ៨០០ រៀល (បីរយប៉ែតសិបប្រាំពីរលានប្រាំពីររយចិតសិបបីពាន់ប្រាំបីរយរៀល) ស្មើនឹង ៩៦ ៩៤៣,៤៥ ដុល្លារអាមេរិក (កៅសិបប្រាំមួយពាន់ប្រាំបួនរយសែសិបបីដុល្លារនិងសែសិបប្រាំសេន) និងមានអ្នកខ្ចីសរុបចំនួន ១៣៧ នាក់ ក្នុងនោះ÷

- ខេត្តត្បូងឃ្មុំ មានផលប័ត្រឥណទានចំនួន ២៥៦ ២៤១ ០០០ រៀល (ពីររយហាសិបប្រាំមួយលានពីររយសែសិបមួយពាន់រយរៀល) សម្រាប់អតិថិជន ៨០ នាក់
- ខេត្តកំពង់ចាមមានផលប័ត្រឥណទានចំនួន ១៣១ ៥៣២ ៨០០ រៀល (មួយរយសាមសិបមួយលានប្រាំរយសាមសិបពីរពាន់ប្រាំបីរយរៀល) សម្រាប់អតិថិជន ៥៧ នាក់។

**៦. គម្រោងអភិវឌ្ឍន៍ជនបទដោយប្រើប្រាស់វិធីសាស្រ្ត "ចលនាភូមិថ្មី"**

- បានបើកវគ្គបណ្តុះបណ្តាល ស្តីពីចលនាភូមិថ្មី និងបច្ចេកទេសចិញ្ចឹមមាន់ ដែលមានសិក្ខាកាមចូលរួមចំនួន ២០ នាក់ ស្រី ០៣ នាក់
- បានរៀបចំពិធីជួបជុំសមាជិកគ្រួសារបុគ្គលិកនៅមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទកម្ពុជា-កូរ៉េដែលមានអ្នកចូលរួមចំនួន ៤៥ នាក់ ស្រី ២៦ នាក់ ក្នុងគោលបំណងបង្ហាញពីរបៀបរបប និងវិន័យនៃការអនុវត្តការងារក្នុងមជ្ឈមណ្ឌល
- បង្កើតទម្រង់វាយតម្លៃមុន និងក្រោយវគ្គបណ្តុះបណ្តាល
- ធ្វើបច្ចុប្បន្នភាពវិន័យនៃការស្នាក់នៅរបស់សិក្ខាកាមក្នុងមជ្ឈមណ្ឌល
- បានបូកសរុបរបាយការណ៍វឌ្ឍនភាពគម្រោងរបស់ភូមិគោលដៅទាំង ៣០ ភូមិ ។

**៧. គម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទទី ២**

គម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទទី ២ បានរៀបចំឡើងដើម្បីជួយធ្វើឱ្យប្រសើរឡើងនូវការងារផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពប្រជាពលរដ្ឋដែលមានលំនៅដ្ឋានជុំវិញបឹងទន្លេសាប ក្នុងខេត្តចំនួន ០៦ គឺ ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ ដែលគាំទ្រដោយហិរញ្ញប្បទានសហប្រតិបត្តិការ និងជំនួយឥតសំណង របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ។ នៅក្នុងខែមិថុនា គម្រោងសម្រេចបាន ÷

- សាងសង់អណ្តូងស្នប់ ចំនួន ១១ អណ្តូង នៅខេត្តបាត់ដំបង

- ស្តារស្រះសហគមន៍ ចំនួន ១៦ នៅខេត្តបន្ទាយមានជ័យ
- ផ្តល់ពាង ចំនួន ៤ ១៨៨ នៅខេត្តបន្ទាយមានជ័យ ពោធិ៍សាត់ និងខេត្តបាត់ដំបង ។

## IV. សេចក្តីសន្និដ្ឋាន

លទ្ធផលអនុវត្តផែនការក្នុងខែមិថុនានេះមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ក្នុងនោះការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទមានល្បឿនលឿនជាងផ្នែកដទៃទៀតដូចជាវិស័យទឹកស្អាត អនាម័យ អភិវឌ្ឍន៍សហគមន៍ជនបទ អភិវឌ្ឍន៍ជនជាតិដើមភាគតិច ។ល។ ចំពោះគម្រោងផ្សេងៗដំណើរការជាប្រក្រតី ដើម្បីឆ្លើយតបនឹងតម្រូវការផ្ទាល់របស់ប្រជាពលរដ្ឋនៅតាមទីជនបទក្នុងការដោះស្រាយរាល់សំណូមពរ កង្វល់ និងសំណើ ដែលបានស្នើឡើងតាមរយៈវេទិការសាធារណៈនាពេលកន្លងមក ហើយបច្ចុប្បន្ននេះក្រសួងកំពុងស្វះស្វែងចរចារកញ្ចប់ថវិកាសម្រាប់ឆ្នាំ ២០១៨ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងគោលដៅជំរុញពន្លឿនការកាត់បន្ថយភាពក្រីក្រនៅទីជនបទដែលបានកំណត់ក្នុងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី ៣ ឱ្យទទួលបានជោគជ័យ ៕

រដ្ឋមន្ត្រី

ឧកញ៉ា អ៊ុក រ៉ាប៊ុន